**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៩៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

### សម្រេច

**មាត្រា១.-**

ត្រូវបានដំឡើងវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពីថ្នាក់នាយកដ្ឋាន ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា២.-**

វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការងារបណ្តុះបណ្តាល និងវិក្រឹតការសមត្ថភាពមន្ត្រីរាជការ លើមុខជំនាញសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានបេសកកម្ម ដូចខាងក្រោម÷

- អនុវត្តការបណ្តុះបណ្តាល និងវិក្រឹតការ លើការគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមទាំងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមបច្ចេកវិទ្យាព័ត៌មាន ជូនមន្ត្រីរាជការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវ និងប្រមូលធាតុចូលស្តីពីការអនុវត្តគោលនយោបាយ និងកម្មវិធីពាក់ព័ន្ធការគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់ពង្រឹង និងកែលម្អការអនុវត្តការងារបណ្តុះបណ្តាល សំដៅលើកកម្ពស់ការយល់ដឹងជូនមន្ត្រីរាជការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រប់គ្រង និងអភិវឌ្ឍប្រព័ន្ធទិន្នន័យបច្ចេកវិទ្យាព័ត៌មាន សម្រាប់គាំទ្រការកសាង និងអភិវឌ្ឍសមត្ថភាពធនធានមនុស្សពាក់ព័ន្ធនឹងការគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ទំនាក់ទំនងជាប្រូយគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័ន ដើម្បីសិក្សាវាយតម្លៃប្រសិទ្ធភាព និងកំណត់អំពីតម្រូវការនៃការស្រាវជ្រាវ ការហ្វឹកហ្វឺន ការបណ្តុះបណ្តាល និងវិក្រឹតការ
- ផ្តួចផ្តើម សម្របសម្រួល និង ជំរុញកិច្ចសហប្រតិបត្តិការលើការងារស្រាវជ្រាវ និងបណ្តុះបណ្តាល ជាមួយនឹងស្ថាប័នស្រាវជ្រាវ និងគ្រឹះស្ថានអប់រំជាតិ និងអន្តរជាតិ ដើម្បីធ្វើទំនើបកម្មកម្មវិធីស្រាវជ្រាវ បណ្តុះបណ្តាល និងវិក្រឹតការ និង លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បោះពុម្ព និងផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវ និងឯកសារសិក្សាសំខាន់ៗ ពាក់ព័ន្ធនឹងបញ្ហាសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំ និង សម្របសម្រួលការផ្ទេរ និង ចែករំលែកចំណេះដឹង ជំនាញ និងឧត្តមានុវត្តន៍ពីទីប្រឹក្សា និងអ្នកជំនាញការ ទាំងក្នុងស្រុក និងអន្តរជាតិ ជូនដល់មន្ត្រីរាជការ គ្រូបង្គោល គ្រូឧទ្ទេស និងសាស្ត្រាចារ្យ
- រៀបចំរបាយការណ៍ស្តីពីសកម្មភាពនៃការស្រាវជ្រាវ ការហ្វឹកហ្វឺន ការបណ្តុះបណ្តាល និងវិក្រឹតការសមត្ថភាពមន្ត្រីរាជការ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា៣.-**

វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដឹកនាំដោយនាយកមួយរូប មានឋានៈ និង បុព្វសិទ្ធិស្មើអគ្គនាយក និង អមដោយនាយករង មួយចំនួន មានបុព្វសិទ្ធិ និងឋានៈស្មើអគ្គនាយករង ជាជំនួយការ ។

នាយកដ្ឋាន ដឹកនាំដោយប្រធានមួយរូប និង អមដោយអនុប្រធានមួយចំនួន ជាជំនួយការ ។

អង្គការលេខរបស់វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា៤.-**

វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរចនាសម្ព័ន្ធដូចខាងក្រោម ÷

- នាយកដ្ឋានបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ
- នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ
- នាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍ ។

**មាត្រា៥.-**

នាយកដ្ឋានបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការងារគ្រប់គ្រងបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ ។

នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ បំពេញការងារជាសេនាធិការឱ្យវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការងារគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាល គ្រូបង្គោល គ្រូឧទ្ទេស សាស្ត្រាចារ្យ និងទំនាក់ទំនងសាធារណៈ ។

នាយកដ្ឋានស្រាវជ្រាវ និង អភិវឌ្ឍ បំពេញការងារជាសេនាធិការឱ្យវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការងារសិក្សាស្រាវជ្រាវ និងអភិវឌ្ឍ ។

**មាត្រា៦.-**

ការរៀបចំ និង ការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា៧.-**

ត្រូវបានលុបបទប្បញ្ញត្តិមួយចំនួន នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចខាងក្រោម÷

- មាត្រា៧ កថាខណ្ឌទី ៥
- ពាក្យ "វិទ្យាស្ថាន" ដែលមានចែងក្នុងមាត្រា ៨
- ពាក្យ "ការបណ្តុះបណ្តាល និងវិក្រឹតការ" ដែលមានចែងក្នុងមាត្រា ១០ ត្រង់ទី ៣
- ពាក្យ "និង មន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធ" ដែលមានចែងក្នុងមាត្រា ១១ ត្រង់ទី ៦
- មាត្រា ១១ ត្រង់ទី ៧
- មាត្រា ១២ ត្រង់ទី ៦
- មាត្រា ១៣ កថាខណ្ឌទី ៦ ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ .៩.៥... អនក្រ.បក ចុះថ្ងៃទី២៣. ខែ កក្កដា.... ឆ្នាំ ២០១៥**

**អង្គការលេខរបស់វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

